ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: ៣៤១០ សក

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
**សូមជម្រាបមក**
**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រីឧកញ៉ា លោក លោកស្រី**
**ជាប្រធានក្រុមហ៊ុនដឹកជញ្ជូនគ្រប់ប្រភេទ**

<u>**កម្មវត្ថុ:**</u> ស្នើសុំក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ ណែនាំអ្នកបើកបររថយន្ត សូមកុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងស្នើសុំឱ្យមានការបិទខិត្តប័ណ្ណ ផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់តាមរថយន្ត។

<u>**យោង:**</u> -លិខិតលេខ ០២ ជក ស្តីពីផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា
- ផែនការសកម្មភាពលេខ០៧៤ ផស/យបគញ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងសាធារណការនិងដឹកជញ្ជូន សូមជម្រាបជូន ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ មេត្តាជ្រាបថា: កន្លងមក យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ ដែលចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ បានបញ្ចប់ប្រកបដោយជោគជ័យ។ តាមលទ្ធផលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ បានបញ្ជាក់ថា អំពើចោរកម្ម អំពើហិង្សាក្នុងសង្គម បានថយចុះគួរឱ្យកត់សម្គាល់ ប៉ុន្តែគ្រោះថ្នាក់ចរាចរណ៍ ពុំមានការកើនឡើងទេ បើប្រៀបធៀបពី៦ខែដើមឆ្នាំ២០១៦ និង៦ខែ ដើមឆ្នាំ២០១៧។ ការពុំមានការកើនឡើងគ្រោះថ្នាក់ចរាចរណ៍នេះ ដោយសារការពង្រឹងច្បាប់ចរាចរណ៍ផ្លូវគោក និងឥទ្ធិពលនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ផង។

ទោះបីជាយ៉ាងណាក៏ដោយ គ្រោះថ្នាក់ចរាចរណ៍តែងតែកើតមានឡើងជាបន្តបន្ទាប់ ដោយសារអ្នកបើកបរខ្លះប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ខ្លះងងុយដេក ខ្លះធ្វេសប្រហែសដោយមិនគោរពច្បាប់ចរាចរណ៍ ខ្លះទៀតគ្មានសីលធម៌ក្នុងការបើកបរ ម៉្យាងទៀតមានកត្តាជាច្រើនទៀតដែរ ដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ដូចជាកត្តាយានយន្ត កត្តាផ្លូវថ្នល់ជាដើម។

ដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ក្រសួងសាធារណការនិងដឹកជញ្ជូន សូមធ្វើការណែនាំដូចខាងក្រោមនេះ÷

១- សូមម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ ណែនាំអ្នកបើកបររបស់ខ្លួន កុំឱ្យប្រើប្រាស់គ្រឿងញៀនដូចជា កញ្ឆា, អាភៀន, ហេរ៉ូអ៊ីន, កាកូអ៊ីន, ICE, WY, ប្រេងម្រះព្រៅ។ល។

២- សូមម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ បិទខិត្តប័ណ្ណផ្សព្វផ្សាយពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនតាមជញ្ជាំងរថយន្តរបស់ក្រុមហ៊ុន។

មហាវិថី ព្រះនរោត្តម ភ្នំពេញ
ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០/៤២៧ ៨៦២

ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងបញ្ជូនក្រុមការងារផ្សព្វផ្សាយ អប់រំ បង្ការការប្រើប្រាស់គ្រឿងញៀនខុសច្បាប់របស់ក្រសួង នឹងចុះពិនិត្យតាមក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ តាមកម្មវិធីរបស់ផែនការសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ របស់រាជរដ្ឋាភិបាល។

ក្រសួងសាធារណការ និងដឹកជញ្ជូន មានសង្ឃឹមយ៉ាងមុតមាំថា **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រីឧកញ៉ា លោក លោកស្រី** ជាប្រធានក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ នឹងធ្វើការណែនាំដល់អ្នកបើកបររបស់ខ្លួនទាំងអស់កុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បើកបរឱ្យមានសីលធម៌ ឱ្យចេះគោរពច្បាប់ចរាចរណ៍ផ្លូវគោក និងឱ្យបានជ្រាបពីផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ នេះ នឹងសហការល្អជាមួយក្រុមការងារផ្សព្វផ្សាយ អប់រំ បង្ការការប្រើប្រាស់គ្រឿងញៀនខុសច្បាប់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដែលនឹងត្រូវចុះធ្វើការត្រួតពិនិត្យតាមក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ នាពេលខាងមុខនេះ។

សូម **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រីឧកញ៉ា លោក លោកស្រី** មេត្តាទទួលនូវការរាប់អាន អំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**ចម្លងជូន:**
- លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២
- ឯកឧត្តម ប្រធានគណៈកម្មាធិការទទួលបន្ទុកផ្សព្វផ្សាយ អប់រំ នៃគណៈកម្មការចុះប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់
  **"ដើម្បីជូនជ្រាប"**
- ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
  **"ដើម្បីសហការ"**
- ឯកសារ កាលប្បវត្តិ